**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងរដ្ឋប្បវេណីលេខ ១២
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩
**សាលក្រមលេខ ៥៥/១២ (គ)**
ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅសាលជម្រះក្តីនៃសាលាដំបូងខេត្តព្រះសីហនុ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

ដើមចោទឈ្មោះ [redacted] CLENTON ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិញូហ្សេលែន [redacted] ប្រពន្ធឈ្មោះ [redacted] សុខកញ្ញា ។

-មានលោក [redacted] ជាអ្នកបកប្រែភាសា ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ អត្តលេខ ១៦១៨ មាន [redacted] ។

ចុងចោទឈ្មោះ [redacted] សុខកញ្ញា ភេទស្រី ជាតិខ្មែរ ថ្ងៃខែឆ្នាំកំណើត១២.០៩.១៩៨២ ទីលំនៅបច្ចុប្បន្ន [redacted] ប្តីឈ្មោះ [redacted] CLENTON ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ អត្តលេខ [redacted] មានការិយាល័យ [redacted] ។

**អង្គហេតុ និង ចំណុចវិវាទ**

**១- សាលក្រមដែលទាមទារដោយដើមចោទ**

ក- សុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

ខ-ផ្តាច់អនីតិសង្វាសរវាងឈ្មោះ [redacted] CLENTON និងឈ្មោះ [redacted] សុខកញ្ញា។

គ-បង្គាប់ឱ្យឈ្មោះ [redacted] សុខកញ្ញា ប្រគល់ដីនិងផ្ទេរសិទ្ធមកឈ្មោះ តំណាង [redacted] CLENTON ឬ តំណាង [redacted] CLENTON ជាកម្មសិទ្ធិករគ្រប់តាត់វែងនូវអចលវត្ថុដូចខាងក្រោម ៖

-ដីមានក្បាលដីលេខ២៦១៩ ទំហំ៥៦០ម²មានទីតាំងស្ថិតនៅភូមិ៥សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០៤០៥-២៦១៩ ចុះថ្ងៃទី០៦ខែមករាឆ្នាំ២០១០ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសូរិយោដីខេត្តព្រះសីហនុ។

-ដីមានក្បាលដីលេខ១១២ទំហំ៦៧១ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ។

-ដីមានក្បាលដីលេខ១១៣ទំហំ៥១៥ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០១-០១១៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ។

-ដីមានក្បាលដីលេខ១១៤ ទំហំ៣៧៣ម² ទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះសីហនុ។

**២. អំពីដំណើររឿងក្តី**

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៤ ឈ្មោះ [redacted] CLENTON បានជួបចាប់ផ្តើមស្រលាញ់គ្នាជាមួយឈ្មោះ [redacted] សុខកញ្ញា ចាប់តាំងពីពេលនោះមកនិងបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ រហូតនៅថ្ងៃទី០៦ខែមិថុនាឆ្នាំ២០១៤ឈ្មោះ [redacted] CLENTON និង

ឈ្មោះ [redacted] សុខកញ្ញា ក៏បានធ្វើពិធីសែនជីដូនជីតាតាមប្រពៃណីជាតិខ្មែរ ដោយមានសាច់ញាតិនិងឪពុកម្តាយរបស់ចុងចម្លើយបានដឹងឮនិងចូលរួមផងដែរ ។

ក្នុងកំឡុងពេលដែលខ្លួនរស់នៅជាមួយភាគីចុងចម្លើយខ្លួនបានទិញដីចំនួន៤កន្លែងនៅខេត្តព្រះសីហនុ ក្នុងគោលបំណងដើម្បីចំណេញប្រាក់តាមការលក់ទិញដី និងដើម្បីស្នាក់នៅរួមគ្នា ដីដែលខ្លួនទិញនោះមានដីមួយមានក្បាលដីលេខ១១២ទំហំ៦៧១ម៉ែមានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០១-០១១២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ដីទំហំ៥១៥ម៉ មានក្បាលដីលេខ១១៣ មានទីតាំងស្ថិនៅភូមិអណ្តូងថ្មស្រុកព្រៃនប់ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៣ចុះថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ២០០៣ ដីដែលមានក្បាលដី១៤៤មានទីតាំងស្ថិនៅភូមិអណ្តូងថ្មស្រុកព្រៃនប់ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៤ចុះថ្ងៃទី២៥០ខែវិច្ឆិកាឆ្នាំ២០០៣និងដីមានក្បាលដីលេខ២៦១៩ទំហំ៥៦០ម៉ែមានទីតាំងស្ថិតនៅភូមិ៥សង្កាត់លេខ៤ក្រុងព្រះសីហនុខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០១០៤០៥-២៦១៩ ចុះថ្ងៃទី០៦ខែមករាឆ្នាំ២០១០ ដែលបានចំណាយទឹកប្រាក់ចំនួន៣២.០០០ដុល្លា(សាមសិបពីរពាន់ដុល្លាអាមេរិក) ដោយសារតែខ្លួនជាជនជាតិបរទេសមិនអាចឈរឈ្មោះឬទិញដីនៅប្រទេសកម្ពុជាបានដូចនេះដីដែលទិញទាំងអស់គឺបានដាក់ឈ្មោះប្រពន្ធខ្លួនតែម្នាក់ឯងហើយចំពោះប្រាក់ដែលយកមកទិញដីទាំងអស់នោះគឺជាប្រាក់ផ្ទាល់ខ្លួនដែលខ្លួនបានសន្សំនៅពេលរស់ដែលខ្លួនរស់នៅប្រទេសញ៉ូហ្សេឡែនមកម្ល៉េះ មិនមែនជាប្រាក់ដែលរកបានពេលដែលរួមរស់ជាមួយចុងចម្លើយនោះទេ ដូចមានលិខិតបញ្ជាក់ផ្ទេរពីធនាគារប្រទេសញ៉ូហ្សេឡែនមកធនាគារកម្ពុជានិងសៀវភៅធនាគាររបស់ខ្លួន ចំណែកចុងចម្លើយបានដឹងយ៉ាងច្បាស់ថា ដីដែលខ្លួនទិញទាំងអស់គឺទិញសំរាប់ផ្ទាល់ខ្លួន និងសំរាប់រស់នៅរហូតដល់ចាស់ស្លាប់នៅទ្រទេសកម្ពុជា។ ដីទំហំ៥៦០ម៉ែមានទីតាំងស្ថិតនៅភូមិ៥ សង្កាត់លេខ៤ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០១០៤០៥-២៦១៩ ចុះថ្ងៃទី០៦ខែមករាឆ្នាំ២០១០ខ្លួនបានសង់ផ្ទះរស់នៅជាមួយចុងចម្លើយដោយចំណាយអស់ទឹកប្រាក់ចំនួន៥៣.៤០០ដុល្លាអាមេរិក។

ប៉ុន្តែក្នុងរយៈពេលចុងក្រោយនេះ ការរួមរស់ជាមួយគ្នារវាងដើមចោទនិងភាគីចុងចម្លើយរស់នៅមិនចុះសម្រុងគ្នា ចេះតែមានការកកាំរកូសទីងគ្នាយ៉ាងខ្លាំង រួចហើយភាគីចុងចម្លើយបានប្រមូលយកវិញ្ញាបនប័ត្រនៃអចលនវត្ថុទាំងអស់ និងគម្រាមថានឹងយកដីទាំងអស់យកទៅលក់ ធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ហើយចុងចម្លើយបានដេញខ្លួនចេញពីផ្ទះថែមទៀត ធ្វើឱ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀតហើយ។ទូងកាត់នីតិវិធីត្រៀមទាញហេតុផលនិងនីតិវិធីទាញ

ហេតុផលដោយផ្ទាល់មាត់ឃើញថាៈ ភាគីដើមចោទឈ្មោះ [redacted] CLENTON បានព្រមព្រៀងគ្នាដោយប្រគល់ដីចំនួន៣ប័ណ្ណឱ្យទៅភាគីចុងចម្លើយឈ្មោះ [redacted] សុខកញ្ញា គឺដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣,ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១២ចុះថ្ងៃទី២៥ ខែវិច្ឆិកាឆ្នាំ២០០៣ និងដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១២ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ និងយល់ព្រមលក់ដីនិងផ្ទះ ដែលមានក្បាល់ដីលេខ២៦១៩ ទំហំ៥៦០ម$^2$មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០១០៤០៥-២៦១៩ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០មានទីតាំងស្ថិតនៅភូមិ៥សង្កាត់លេខ២ក្រុងព្រះសីហនុខេត្តព្រះសីហនុ របស់មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសូរិយោដី ខេត្តព្រះសីហនុ នាថ្ងៃផ្តិតស្នាមមេដៃលើកិច្ចព្រមព្រៀង ដោយធ្វើការបែងចែកប្រាក់ថ្លៃលក់ជាពីរចំណែកស្មើគ្នា ដោយភាគីទាំងពីរយល់ព្រមកំណត់តម្លៃលក់យ៉ាងតិចស្មើ៦០០ដុល្លា(ប្រាំមួយរយដុល្លាអាមេរិក) ក្នុងមួយម៉ែត្រក្រឡា ឬតាមការព្រមព្រៀងរបស់គូភាគី។ ហើយចំពោះភាគីដើមចោទសុខចិត្តប្រគល់កូនប្រុសឈ្មោះ [redacted] គីមមិនា កើតនៅថ្ងៃទី២២ខែមីនាឆ្នាំ២០១៥អោយទៅភាគីចុងចម្លើយជាអ្នកមានអំណាចមេបាទីងប្រគល់ប្រាក់ចំនួន១០.០០០ដុល្លា(មួយម៉ឺនដុល្លាអាមេរិក) បន្ទាប់ពីលក់ដីផ្ទះដាច់និងបែងចែកគ្នារួចរាល់។

## ៣. សេចក្តីថ្លែងការណ៍របស់គូភាគី

### ៣.១. សេចក្តីថ្លែងការណ៍របស់ដើមចោទ

ឈ្មោះ [redacted] CLENTONបានថ្លែងការណ៍ថា ខ្លួនសូមរក្សាអង្គហេតុបញ្ជាក់ការទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ដដែល។ ប៉ុន្តែសុំកែប្រែកម្មវត្ថុបណ្តឹងពីការសុំគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់មកជាសុំបែងចែកទ្រព្យសម្បត្តិដីដែលមានទំហំ៥៦០ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ៥ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ១៨០១០៤០៥-២៦១៩ចុះថ្ងៃទី០៦ខែមករាឆ្នាំ២០១០ ជាពីរចំណែកស្មើគ្នា។

រីឯដីចំនួន៣ប័ណ្ណដែលមានក្បាលដីលេខ១១២ ទំហំ៦៧១ម$^2$ មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានវិញ្ញាណប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០១-០១១២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-ដីមានក្បាលដីលេខ១១៣ទំហំ៥១៥ម$^2$មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានវិញ្ញាណប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។



Scanned with CamScanner

-ដីមានក្បាលដីលេខ១១៤ទំហំ៣៧៣ម៉ែមានទីតាំងស្ថិតនៅភូមិអណ្ដូងថ្ម សង្កាត់អណ្ដូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០១-០១១៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

ខ្លួនសុខចិត្តប្រគល់ទៅអោយចុងចម្លើយឈ្មោះ [redacted] សុខកញ្ញា គ្រប់គ្រងជាកម្មសិទ្ធ ។ ហើយសុខចិត្តប្រគល់កូនប្រុសឈ្មោះ [redacted] តីមមិនា កើតនៅថ្ងៃទី២២ខែមីនាឆ្នាំ២០១៥ អោយទៅភាគីចុងចម្លើយជាអ្នកមានអំណាចមេបាទីងប្រគល់ប្រាក់ចំនួន១០.០០០ដុល្លា (មួយម៉ឺនដុល្លាអាមេរិក) បន្ទាប់ពីលក់ដីផ្ទះដាច់ និងបែងចែកគ្នារួចរាល់។

### ៣.២. សេចក្ដីថ្លែងការណ៍របស់មេធាវីដើមចោទ

លោកមេធាវី [redacted] និងលោកមេធាវី [redacted] បានថ្លែងការណ៍ថា ក្នុងរឿងនេះគូភាគីបានព្រមព្រៀងគ្នាបែងចែងទ្រព្យនិងផ្ទះរួចរាល់អស់ហើយហេតុដូច្នេះខ្លួនជាមេធាវីតំណាងដោយអាណត្តិសូមអោយលោកចៅក្រមសម្រេចតាមការព្រមព្រៀងរបស់ដើមចោទនិងចុងចម្លើយ។

សំណូមពរ

១.សុំបញ្ឈប់ការរស់នៅបែបអនីតិសង្វាស ។

២.សុំបែងចែកទ្រព្យសម្បត្តិ។

### ៣.៣. សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ

ឈ្មោះ [redacted] សុខកញ្ញា បានថ្លែងការណ៍ថា ខ្លួនឯកភាពចំពោះសេចក្ដីថ្លែងការណ៍របស់ដើមចោទទាំងស្រុង។

### ៣.៤. សេចក្ដីថ្លែងការណ៍របស់មេធាវីចុងចម្លើយ

លោកមេធាវី [redacted] បានថ្លែងការណ៍ថា ខ្លួនសូមឯកភាពចំពោះសេចក្ដីថ្លែងការណ៍របស់កូនក្ដីខ្លួន ។

### ៤.ចំណុចវិវាទ

- គូភាគីមិនសះជាតនឹងគ្នា ។

### ៥.ចំណុចគ្មានវិវាទ

-គូភាគីឯកភាពលែងលះ ឯកភាព បែងចែកទ្រព្យ និងឯកភាពប្រគល់សិទ្ធគ្រប់គ្រងកូន។

## សំអាងហេតុ

-ឈ្មោះ [redacted] CLENTON និងប្រពន្ធឈ្មោះ [redacted] សុខកញ្ញា បានរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធបែបអនីតិសង្វាសនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤ តែពុំបានចុះសំបុត្រអាពាហ៍

ពិពាហ៍ឡើយការរួមរស់ជាមួយគ្នាមានកូនប្រុសមួយឈ្មោះ [redacted] គឺមមិនា កើតនៅថ្ងៃទី២២ខែមីនា ឆ្នាំ២០១៥ហើយចំពោះទ្រព្យសម្បត្តិមានដីដែលមានក្បាលដីលេខ១១២ទំហំ៦៧១ម² មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣។

-ដីមានក្បាលដីលេខ១១៣ទំហំ៥១៥ម² មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-ដីមានក្បាលដីលេខ១១៤ទំហំ៣៧៣ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០១-០១១៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-ដីដែលមានទំហំ៥៦០ម៉ែត្រការ៉េមានទីតាំងស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ១៨០១០៤០៥-២៦១៩ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០។

ចំពោះទ្រព្យសម្បត្តិនេះគូភាគីឯកភាពគ្នាប្រគល់ដីចំនួន៣ប័ណ្ណដែលមាន ៖

-ដីមានក្បាលដីលេខ១១២ទំហំ៦៧១ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-ដីមានក្បាលដីលេខ១១៣ទំហំ៥១៥ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០១-០១១៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-ដីមានក្បាលដីលេខ១១៤ទំហំ៣៧៣ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៤ ចុះថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ២០០៣ អោយទៅចុងចម្លើយឈ្មោះ [redacted] សុខកញ្ញា គ្រប់គ្រងជាកម្មសិទ្ធ។

ចំណែកដីផ្ទះដែលមានទំហំ៥៦០ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ៥សង្កាត់លេខ៤ក្រុងព្រះសីហនុខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ ១៨០១០៤០៥-២៦១៩ ចុះថ្ងៃទី០៦ខែមករាឆ្នាំ២០១០ គូភាគីបានព្រមព្រៀងបែងចែកស្មើគ្នា។

រីឯកូនប្រុសម្នាក់ឈ្មោះ [redacted] គឹមមិនា កើតនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៥ គូរភាគីឯកភាពគ្នាប្រគល់ទៅឱ្យភាគីចុងចម្លើយជាអ្នកមានអំណាចមេបានីងដើមចោទប្រគល់ប្រាក់ចំនួន

១០.០០០ដុល្លា(មួយម៉ឺនដុល្លាអាមេរិក)បន្ទាប់ពីលក់ដីផ្ទះដាច់ និងបែងចែកគ្នារួចរាល់ទៅចុងចម្លើយ។

-ការឯកភាពគ្នារវាងដើមចោទនិងចុងចម្លើយ ដូច្នេះតុលាការគប្បីសម្រេចតាមព្រមព្រៀង ។

បានពិនិត្យវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ ១៨០១០៤០៥-៤៦១៩ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ទំហំ៥៦០ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

បានពិនិត្យវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០៦-០១១២ ចុះថ្ងៃទី២៥ ខែវិច្ឆិកាឆ្នាំ២០០៣ក្បាលដីលេខ១១២ទំហំ៦៧១ម²មានទីតាំងស្ថិតនៅភូមិអណ្តូង ថ្មស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

បានពិនិត្យវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០៦-០១១៣ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ដីលេខ១១៣ទំហំ៥១៥ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុ។

បានពិនិត្យវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០៦-០១១៤ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ក្បាលដីលេខ១១៤ ទំហំ៣៧៣ម² មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

បានពិនិត្យរូបថតចំនួន៣សន្លឹកដែលបានសែនព្រេនទៅតាមប្រពៃណីខ្មែររបស់គូរភាគី។

បានពិនិត្យកិច្ចសន្យាព្រមព្រៀងសះជាបញ្ចប់វិវាទ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់គូរភាគី។

-សេចក្តីចម្លងសំបុត្រកំណើតរបស់ឈ្មោះ [redacted] គីមមិនា ចុះថ្ងៃទី២៧ខែមេសាឆ្នាំ២០១៥។

-ប្រាក់ប្រដាប់ក្តីគប្បីជាបន្ទុករបស់ដើមចោទ។

## សេចក្តីសម្រេចបញ្ចប់

១.បញ្ឈប់ការរស់នៅបែបអនីតិសង្វាសរវាងដើមចោទឈ្មោះ [redacted] CLENTON និងចុងចម្លើយឈ្មោះ [redacted] **សុខកញ្ញា** ចាប់ពីពេលនេះតទៅ។

២. ប្រគល់កូនប្រុសម្នាក់ឈ្មោះ [redacted] **គីមមិនា** កើតនៅថ្ងៃទី២២ខែមីនាឆ្នាំ២០១៥ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **សុខកញ្ញា** គ្រប់គ្រងញ៉ាំមបីបាច់ថែរក្សា ចាប់តាំងពីពេលនេះទៅ តាមការព្រមព្រៀងរបស់គូភាគី។

៣.អំពីទ្រព្យសម្បត្តិ ៖

ក.ដីផ្ទះដែលមានទំហំ៥៦០ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ ១៨០១០៤០៥-២៦១៩ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ បែងចែកជាពីរចំណែកស្មើគ្នា រវាងដើមចោទឈ្មោះ [redacted] CLENTON និងចុងចម្លើយឈ្មោះ [redacted] **សុខកញ្ញា** តាមការព្រមព្រៀងរបស់គូភាគី។

ខ.ប្រគល់ ៖

-ដីដែលមានក្បាលដីលេខ ១១២ ទំហំ៦៧១ម² មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុ មានវិញ្ញាណប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០ ២០១០១-០១១២ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-ដីដែលមានលេខ១១៣ទំហំ៥១៥ម²មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៨០២០១០១-០១១៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-ដីដែលមានលេខ ១១៤ ទំហំ ៣៧៣ម² មានទីតាំងស្ថិតនៅភូមិអណ្តូងថ្ម សង្កាត់អណ្តូងថ្ម ស្រុកព្រៃនប់ខេត្តព្រះសីហនុមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២០១០១-០១១៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **សុខកញ្ញា** ជាកម្មសិទ្ធិចាប់តាំងពីពេលនេះទៅតាមការព្រមព្រៀងរបស់គូភាគី។

៤.ឱ្យដើមចោទប្រគល់ប្រាក់ចំនួន ១០.០០០ ដុល្លា(មួយម៉ឺនដុល្លាអាមេរិក)ទៅចុងចម្លើយតាមការព្រមព្រៀង នៅពេលគូភាគីលក់ដី និងផ្ទះនៃចំណុច ទី៣(ក)បាន។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃអង្គារ ៨រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩។

**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ខេត្តព្រះសីហនុ, ថ្ងៃទី 11 ខែ12ឆ្នាំ2019

[redacted]